


# ការវិនិយោគលើផលិតផលដើម ឫស្សី នៅកម្ពុជា

ទីផ្សារផលិតផលដើមឫស្សី ត្រូវបានបែងចែកជាច្រើនផ្នែកដោយមានផ្នែកសំខាន់ពីរគឺចង្កឹះនិងឈើចាក់ធ្មេញ។ ផលិតផលដើមឫស្សីផ្សេងៗ រួមមានចង្កាក់សាច់អាំង ជើងធូប កន្ទេលឫស្សី និងរនាំង ឫស្សី ហើយផលិតផលនីមួយៗសុទ្ធសឹងតែមានសារៈសំខាន់នៅលើទីផ្សារផ្សេងៗ។

| | | | | |
|---|---|---|---|---|
|  |  |  |  |  |
| ចង្កឹះឫស្សី | ចង្កាក់ឫស្សី | ឈើចាក់ធ្មេញឫស្សី | ជើងធូបឫស្សី | កន្ទេលឫស្សី |

ផលិតផលដើមឫស្សី កំពុងតែទទួលបានឱកាសទីផ្សារ តាមរយៈការទទួលស្គាល់ពីអតិថិជន អំពីអត្ថប្រយោជន៍ដើមឫស្សីផ្នែកបរិស្ថាន និងនៅក្នុងករណីជាច្រើន ការប្រកួតប្រជែងខ្លាំងអំពីចង្កឹះឫស្សីលើភាពល្អប្រសើរជាងផលិតផលធ្វើពីឈើ និងជាពិសេសកំណើននៅក្នុងទីផ្សារអាស៊ី។

## ផលិតផលនិងទីផ្សារ

ទីផ្សារពិភពលោកសម្រាប់ចង្កឹះឫស្សី ត្រូវបានប៉ាន់ប្រមាណថា មានតម្លៃ ៣០០លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៦[១]។ ខណៈដែលទីផ្សារពិភពលោកសម្រាប់ចង្កឹះ ទូទៅត្រូវបានប៉ាន់ប្រមាណថានឹងមានតម្លៃ៤០០លានដុល្លារអាមេរិក[២]។ ប្រទេសចិនគឺជាប្រទេសផលិតចង្កឹះដ៏ធំបំផុតហើយប្រទេសចិនក៏ជាប្រទេស ប្រើប្រាស់ចង្កឹះដ៏ច្រើនជាងគេបំផុត នៅក្នុងពិភពលោកផងដែរ។ យោងតាមស្ថិតិ របស់ប្រទេសចិននៅក្នុងឆ្នាំ២០១១ រោងចក្រផលិតរបស់ប្រទេសចិន តែងផលិតចង្កឹះចំនួន ៦០ ទៅ ៨០ ពាន់លានគូនៅក្នុងមួយឆ្នាំៗ។ ៤០%នៃផលិតកម្មត្រូវបានប្រើប្រាស់សម្រាប់ទីផ្សារក្នុងស្រុកនិង ៦០%ត្រូវបាននាំចេញ។ យោងតាមស្ថិតិរបស់ក្រុមហ៊ុន

**Contact information:**

ww.aha-kh.com/bamboo

bamboo@aha-kh.com

+855 89 595 668 (English)

+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង

## ឫស្សីៈសម្ភារៈសំរាប់អនាគត

Comtrade បានឲ្យដឹងថា ការនាំចេញចង្កឹះឫស្សី និងចង្កឹះនានារបស់ ប្រទេសចិនបានកើនដល់ ១០៥ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០០៨ (៧៥.៥លានដុល្លារអាមេរិក សម្រាប់ចង្កឹះចាប់អាហារ និង ២៩.៥ លានដុល្លារអាមេរិក សម្រាប់ផលិតផលចង្កឹះដ៏ទៃផ្សេងៗ។) ប្រទេសនាំចូលចង្កឹះដ៏សំខាន់ៗរបស់ប្រទេសចិន គឺមាន ប្រទេសជប៉ុន និង ប្រទេសកូរ៉េខាងត្បូង។ ប្រទេសជប៉ុន ឈរនៅក្នុងលំដាប់លេខពីរ នៅក្នុងការប្រើប្រាស់ចង្កឹះ។ ក្នុងមួយឆ្នាំៗប្រទេសជប៉ុន តែងប្រើប្រាស់ចង្កឹះហូបបោះចោលចំនួន ២៣ទៅ២៥ពាន់លានគូ គឺប្រហែលចំនួន២០០គូ សម្រាប់ការប្រើប្រាស់របស់មនុស្សម្នាក់។ កក្តារប្រើប្រាស់នេះ គឺមានកម្រិតខ្ពស់ដែលធ្វើឲ្យរដ្ឋាភិបាលជប៉ុន

បន្ថែមពន្ធលើចង្កឹះឈើ។នៅក្នុងការឆ្លើយតបនេះក្រុមហ៊ុននាំចូលរបស់ប្រទេសជប៉ុនបានចាប់ផ្តើមទិញចង្កឹះឫស្សីដែលជាសម្ភារៈនិងដែលមាននិរន្តរភាពខ្ពស់ជាង។អ្នកប្រើប្រាស់ចង្កឹះដ៏សំខាន់ផ្សេងទៀតនៅក្នុងពិភពលោក គឺប្រទេសកូរ៉េ តៃវ៉ាន់ វៀតណាម កម្ពុជា និងឡាវ។ ទិន្នន័យជឿទុកចិត្តបានអំពីផលិតផល ដើមឫស្សីផ្សេងៗ មិនអាចត្រូវបានកំណត់នៅឡើយទេ ប៉ុន្តែឈើចាក់ធ្មេញឫស្សី ជើងធូបឫស្សី និងចង្កាក់អាំង សាច់ គឺមានសម្បូរបែប នៅលើទីផ្សារនានា នៅក្នុងអាស៊ី ព្រមទាំងទីផ្សារបស្ចឹមប្រទេស។ កន្ទេល និង រនាំង ឫស្សី គឺពេញនិយមយ៉ាង ខ្លាំងនៅអាស៊ីនិងទទួលបានចំណាប់អារម្មណ៍ទីផ្សារនៅក្នុងទីផ្សារបស្ចឹមប្រទេស។ នៅក្នុងប្រទេស កម្ពុជាចង្កឹះឫស្សីប្រើហើយបោះចោលត្រូវបានប្រើប្រាស់ទូទៅក្នុងភោជនីយដ្ឋាន។ សព្វថ្ងៃនេះចង្កឹះ ឫស្សីដែលប្រើហើយបោះចោលបាននាំចូលមកពីប្រទេសវៀតណាម និងប្រទេសចិន។ នៅក្នុង ប្រទេសកម្ពុជា តំរូវការប្រើប្រាស់ចង្កឹះប្រភេទនេះ ត្រូវបានគេប៉ាន់ប្រមាណ បី បួនលានតោនក្នុងមួយឆ្នាំៗ។ អង្គការ GIZ



កីឫស្សី និងកន្ទេលឫស្សី និងផលិតផលកម្រាល

**Contact information:**

ww.aha-kh.com/bamboo

bamboo@aha-kh.com

+855 89 595 668 (English)

+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង



## ឫស្សីៈសម្ភារៈសំរាប់អនាគត

កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ក្រវាត់បៃតងខេត្តសៀមរាបកំពុងធ្វើការសិក្សា ទីផ្សារចង្កឹះឬស្សីសម្រាប់ទីផ្សារក្នុងស្រុកនៅប្រទេសកម្ពុជា។

## បច្ចេកវិទ្យាកែច្នៃ

ស្តង់ដានៃដំណើរការផលិតផលិតផលដើមឫស្សី ត្រូវបានបរិយាយនៅក្នុងដ្យាក្រាមខាងក្រោម។ សមត្ថភាពផលិតកម្ម អាចប្រែប្រួលពី៣០តោនទៅ២៥០តោន នៃផលិតផលសម្រេចនៅក្នុងមួយ ឆ្នាំៗ អាស្រ័យលើទំហំនៃការវិនិយោគនិងការប្រើប្រាស់បច្ចេកទេស។ គ្រឿងយន្ត និងគ្រឿងបរិក្ខារ អាចត្រូវបានគេទិញនៅក្នុងប្រទេសចិន និងវៀតណាម។ ប្រព័ន្ធគ្រឿងបរិក្ខារធម្មតា គឺមានតម្លៃជិត ១០,០០០ដុល្លារអាមេរិក ខណៈដែលគ្រឿងបរិក្ខារដ៏ទំនើប និងបច្ចេកទេសខ្ពស់ អាចមានតម្លៃដល់ ៥០,០០០ដុល្លារអាមេរិក។

១. ការការតម្រឹម → ២. ការពុះច្រៀក → ៣. ការតម្រៀប (២ទៅ៥បន្ទះ) → ៤. ការកំណត់ទំហំចង្កឹះ → ៥. ការខាត់ ឲ្យរលោង → ៦. ការតម្រឹមប្រវែង → ៧. ការសម្រួចក្បាល → ៨. ការវេចខ្ចប់

របៀបនៃផលិតកម្មចង្កឹះឬស្សី

បច្ចេកវិទ្យាផលិតចង្កឹះដើមឫស្សី ត្រូវបានបែងចែកជាពីរកម្រិតគឺៈ

**១.** បច្ចេកវិទ្យាកម្រិតទាប គឺមានលក្ខណៈសាមញ្ញបំផុតនិងត្រូវការវិនិយោគដើមទុនទាបបំផុត ប៉ុន្តែអត្រាប្រើប្រាស់វត្ថុធាតុដើមឫស្សីគឺមានកម្រិតទាប(៨ទៅ១០%)។ប្រការនេះបង្កឲ្យមានការខ្ជះខ្ជាយ និងមានកាកសំណល់យ៉ាងច្រើនហើយតម្លៃពាណិជ្ជកម្មគិតជាប្រាក់ចំណេញនៃផលិតផលសម្រេចមានកម្រិតទាប។



ម៉ាស៊ីនសម្រួចក្បាលចង្កឹះ

**Contact information:**

ww.aha-kh.com/bamboo

bamboo@aha-kh.com

+855 89 595 668 (English)

+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង

## ឫស្សីៈសម្ភារៈសំរាប់អនាគត

២. បច្ចេកវិទ្យាកម្រិតខ្ពស់ គឺមានលក្ខណៈស្មុគស្មាញជាងបន្តិចតែប៉ុណ្ណោះ និង តម្រូវឲ្យមានការវិនិយោគដើមទុនច្រើនជាង។ វាមានអត្រាប្រើប្រាស់កម្រិតខ្ពស់ (២០% ទៅ ២៥%) និងជាធម្មតាផលិតផលល្អប្រណិត តែងផ្តល់ប្រាក់ចំណេញកាន់តែប្រសើរសម្រាប់វិនិយោគិន ។

## វត្ថុធាតុដើម

ការវាយតម្លៃលើធនធានដើមឫស្សីនៅក្នុងស្រុកវ៉ារិនខេត្តសៀមរាបបង្ហាញថាពូជឫស្សីនិងបរិមាណសមស្របមានគ្រប់គ្រាន់។ ផែនការគាំទ្រចំពោះការអភិវឌ្ឍន៍ការដាំដុះដើមឫស្សីនឹងធានាដល់ការ ផ្គត់ផ្គង់រយៈពេលយូរ។ ឫស្សីព្រៃ គឺជាវត្ថុធាតុសមស្របមានច្រើនលើស លុប។ រោងសិប្បកម្មតូចមួយ ជាមួយបច្ចេកវិទ្យាកម្រិតទាបដោយផលិតបាននូវផលិតផលសម្រេច ៣០តោនក្នុងមួយឆ្នាំ នឹងអាចប្រើប្រាស់ដើម ឫស្សីស្រស់ចំនួន៣០០តោន នៅក្នុងមួយឆ្នាំៗ។ ខណៈដែលរោងចក្រដែលមានបច្ចេកទេសកម្រិតខ្ពស់ ដោយមានសមត្ថភាពផលិត ២៥០តោននៅក្នុងមួយឆ្នាំត្រូវការដើមឫស្សីស្រស់១០០០តោននៅក្នុងមួយឆ្នាំ។



ឫស្សីព្រៃ

## ផែ្នកហិរញ្ញវត្ថុ

គំរូហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់សម្រាប់តំណាងផលចំណូលហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគនៅក្នុងបរិបទនៃវិនិយោគិនកម្ពុជានៅក្នុងស្រុកវ៉ារិន។ សូចនាករលទ្ធភាពចំណេញដ៏សំខាន់ៗគឺគួរឲ្យ ទាក់ទាញ។ នៅក្នុងករណីនៃការវិនិយោគលើបច្ចេក វិទ្យាខ្ពស់ រយៈពេលនៃការស្រង់ដើមទុនមកវិញ ត្រូវ បានព្យាករណ៍ថានឹងត្រូវការរយៈពេល២ឆ្នាំ និង ៤ខែ ដែលនៅក្នុងនោះ អត្រាចំណូលប្រចាំឆ្នាំធៀប នឹង ទ្រព្យម្ចាស់ (ROE) អាចកើនដល់ ៣៩% ជាមធ្យម សម្រាប់គម្រោងរយៈពេល១០ឆ្នាំ កម្រិតផលចំណេញសុទ្ធ(NOPAT)អាចនឹងដល់២៨% ជាមធ្យម។

| សូចនាករលទ្ធភាពចំណេញ | ឧបសម្ព័ន្ធ | ឯកតា |
|---|---|---|
| EBITDA[1]កម្រិតចំណូល | 37.0 | % |
| ប្រាក់ចំណូលសុទ្ធ | 28.2 | % |
| ចំណូលធៀបនឹងទ្រព្យម្ចាស់ | 38.7 | % |
| ចំណូលពីទ្រព្យ | 34.7 | % |
| អត្រាចំណូលផ្ទៃក្នុង | 123 | % |
| តម្លៃដុលបច្ចុប្បន្ន | 0.35 | លាន USD |
| រយៈពេលស្រង់ដើមទុន | 2.3 | ឆ្នាំ |

**Contact information:**

ww.aha-kh.com/bamboo

bamboo@aha-kh.com

+855 89 595 668 (English)

+855 12 550 635 (Khmer)